# វគ្គបណ្ដុះបណ្ដាលវាលទាំងបួន

## <u>និមិត្ត</u>

## <u>ការចូលទៅកាន់វាលថ្មី</u>

## <u>ដំណឹងល្អ</u>

## <u>ការបង្កើតសិស្ស</u>

- កិច្ចការ ជំពូក២ និង បទបញ្ហាទាំង៧
- ដំណើរការជំហានទាំង៨
- ការបង្កើតសិស្សរយៈពេលវែង

## <u>ការបង្កើតក្រុមជំនុំ</u>

- ការសិក្សាពីក្រុមជំនុំដែលសាមញ្ញ

## <u>ការបង្កើតគោលដៅ</u>

# ការសិក្សាបន្ថែម

## <u>យុទ្ធសាស្ត្រភ្លេងលឿន</u>

## <u>ការសិក្សាអំពីការជ្រមុជ</u>

# មាតិកាបណ្តុះបណ្តាលទី១អំពីវាលទាំបួន

# និមិត្ត

## តើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ជាអ្វី?

<u>ម៉ាឡាគី១៖១១</u>

*11ចាប់ពីទិសខាងកើត រហូតដល់ទិសខាងលិច នាមរបស់យើងប្រសើរឧត្ដុង្គឧត្ដមក្នុងចំណោមប្រជាជាតិនានា។ នៅគ្រប់ទីកន្លែង គេនាំគ្នាដុតគ្រឿងក្រអូបដើម្បីលើកតម្កើងនាមរបស់យើង ព្រមទាំងនាំយកតង្វាយបរិសុទ្ធមកជាមួយផង ដ្បិតនាមរបស់យើងប្រសើរឧត្ដុង្គឧត្ដម ក្នុងចំណោមប្រជាជាតិនានា - នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល។*

## តើអ្វីទៅជាផែនការណ៏របស់ព្រះជាម្ចាស់

ម៉ាថាយ១៦៖១៦-១៩ និង ម៉ាថាយ ២៨៖១៨-២០

ព្រះយេស៊ូមានព្រះបន្ទូលថា ទ្រង់នឹងសង់ក្រុមជំនុំរបស់ទ្រង់។ យើងត្រូវតែចេញទៅ ផ្សាយដំណឹងល្អ បង្កើតសិស្ស និង ប្រមូលពួកគេឲ្យចូលរួមគ្នា។ ហើយយើងត្រូវបង្រៀនអ្នកដ៏ទៃទៀតឲ្យធ្វើរឿងដូចគ្នានេះ។




បន្ទាប់ពីសិក្សាខគម្ពីរទាំងនេះរួចហើយ សូមគូសរូបភាពខាងក្រោមជារូបភាពដែលជួយយើងឲ្យចងចាំពីផែនការរបស់ព្រះជាម្ចាស់ (ម៉ាថាយ១៦៖១៦-១៩ និង ម៉ាថាយ ២៨៖១៨-២០) សម្រាប់ការឈោងចាប់មនុស្សទាំងអស់ និង គ្រប់ទីកន្លែងទាំងអស់។



## ការចូលទៅកាន់ (វាលទី១)

មានមនុស្សពីរប្រភេទផ្សេងគ្នាៈ ជាមនុស្សដែលលោកអ្នកស្គាល់ និង មនុស្សដែលលោកអ្នកមិនដែលស្គាល់។ យើងបង្កើតផែនទីអយកុសដើម្បីជួយយើងគិតពីអស់អ្នកដែលមិនទាន់ជឿដែលមាននៅក្នុងជីវិតរបស់យើងរួចស្រេច។ យើងសិក្សាពីលូកា១០ៈ១-១១ ដើម្បីចូលទៅកាន់មនុស្សដែលយើងមិនដែលស្គាល់ពីមុនមក។




**អយកុស**

**សូមអាន យ៉ូហាន១ៈ៣៥-៤២**

តើអ្នកណាបានជឿ? ហើយតើអ្នកណាដែលគាត់បានចេញទៅហើយប្រាប់មុនគេ?

លោកអនទ្រេ បានចេញទៅប្រាប់បងប្រុសរបស់គាត់ឈ្មោះថា ស៊ីម៉ូនពេត្រុស (ខ៤១)។

**ចូរបង្កើតផែនទីអយកុស**

**លូកា១០**

**សូមអាន លូកា១០ៈ១- ១១**

| តើមានអ្វីខ្លះដែលព្រះប្រាប់ពួកសិស្សឲ្យធ្វើ? | តើមានអ្វីខ្លះដែលព្រះប្រាប់ពួកសិស្សមិនឲ្យធ្វើ? |
|---|---|
| • ២x២ (ខ១)<br>• អធិស្ឋាន (ខ២)<br>• ចេញទៅ (ខ៣)<br>• ផ្តល់សេចក្តីសុខសាន្ត/ ជម្រាបសួរនៅផ្ទះណាដែលទទួលយើង(ខ៥)<br>• ស្នាក់នៅផ្ទះនោះ (ខ៧)<br>• ប្រកាសប្រាប់ពីព្រះរាជ្យ/ដំណឹង (ខ៩)<br>• រលាស់ធូលីដីចេញពីជើង (ខ១០) | • កុំយកកាបូបលុយ ថង់យាម ឬស្បែកជើងទៅជាមួយ (ខ៤)<br>• កុំជម្រាបសួរអ្នកណានៅតាមផ្លូវ (ខ៤)<br>• កុំចេញពីផ្ទះមួយទៅផ្ទះមួយ (ខ៧) |

**វាលទាំង៤ និង ការសិក្សាបន្ថែម**

សូមជ្រើសរើសអត្ថបទពីរក្នុងចំណោមអត្ថបទទាំងអស់ខាងក្រោមដើម្បីប្រៀបធៀបជាមួយសេចក្តីណែនាំនៅក្នុងលូកាជំពូក១០។ តើមានសកម្មភាពអ្វីខ្លះដែលដូចគ្នារវាងអត្ថបទនៅក្នុងសៀវភៅលូកា និង សៀវភៅកិច្ចការ?

**កិច្ចការ១៦៖១១-១៥**

- ២x២ (ខ១៣ "យើង"
- អធិស្ឋាន (ខ១៣ "ចេញទៅរកកន្លែងអធិស្ឋាន")
- ចេញទៅ (ខ១៣)
- ផ្សាយដំណឹងល្អ (ខ១៣,១៤)
- ស្នាក់នៅផ្ទះមួយ (ខ១៥)

**កិច្ចការ ១៦៖២៥-៤០**

- ២x២ (ខ២៥ ប៉ូល និង ស៊ីឡាស)
- អធិស្ឋាន (ខ២៥)
- ផ្សាយដំណឹងល្អ (ខ៣១-៣២)
- ស៊ី និង ផឹក (ខ៣៤)
- ស្នាក់នៅផ្ទះមួយ (ខ៣៤)

**កិច្ចការ១០៖១-៤៨**

- ២x២ (ខ២៣ លោកពេត្រុស និង បងប្អូនឯទៀតៗ)
- អធិស្ឋាន (ខ៩)
- ចេញទៅ (ខ២៣)
- ស្នាក់នៅផ្ទះមួយ (ខ៤៨)
- ផ្សាយដំណឹងល្អ (ខ៣៤-៤៣)

**កិច្ចការ ១៨៖១-១១**

- ២x២ (ខ១,៥ លោកប៉ូល នាងប្រេស៊ីល និង លោកអគីឡា)
- ចេញទៅ (ខ៧)

**វាលទាំង៤ និង ការសិក្សាបន្ថែម**

- ស្នាក់នៅផ្ទះមួយ (ខ១១)
- ផ្សាយដំណឹងល្អ (ខ៨)

**សេចក្ដីសន្និដ្ឋាន៖** តាមរយៈលូកា១០៖១-១១និងអត្ថបទគម្ពីរផ្សេងៗនៅក្នុងព្រះគម្ពីរកិច្ចការយើងបានឃើញគំរូនៃការចេញទៅ ពីរពីរនាក់ ការអធិស្ឋាន ប្រកាសដំណឹងល្អ ហើយស្នាក់នៅក្នុងផ្ទះរបស់អស់អ្នកដែលជឿ។

ដូច្នេះ ចូលទូលសុំព្រះថាតើលោកអ្នកនឹងចេញទៅណាដើម្បីអនុវត្តន៏លូកាជំពូក ១០។

## ដំណឹងល្អ (វាលទី២)

---

**២-៣-៤**

**២៖ មានពីរផ្នែក:** សាច់រឿងរបស់យើង និង សាច់រឿងរបស់ព្រះយេស៊ូ (ដំណឹងល្អ)

**៣៖ សាច់រឿងរបស់យើងមានបីផ្នែក**

១. ជីវិតមុនពេលជឿព្រះយេស៊ូ

២. ជួបព្រះយេស៊ូដោយរបៀបណា

៣. ជីវិតក្រោយពេលជឿព្រះយេស៊ូ



**៤៖ សាច់រឿងរបស់ព្រះយេស៊ូមាន ៤ផ្នែក**

១. ការបង្កើត

២. អំពើបាប

៣. ការសុគតរបស់ព្រះយេស៊ូ ការកប់នៅក្នុងផ្នូរ និង ការរស់ឡើងវិញ (១កូរិនថូស ១៥៖៣-៤)

៤. ជម្រើស

នៅខាងក្រោមនេះជារបៀបមួយដ៏សាមញ្ញ ហើយជារបៀបដែលអាចបង្កើតដ៏ល្អដើម្បីផ្សាយដំណឹងល្អ ដោយប្រើដៃរបស់អ្នក៖

**វាលទាំង៤ និង ការសិក្សាបន្ថែម**

១. នេះជាព្រះ (ចង្អុលដៃ)

ហើយនេះជាមនុស្ស (មេដៃ)



២. នៅដើមដំបូងបង្អស់មនុស្សមាន

ទំនាក់ទំនងល្អឥតខ្ចោះជាមួយព្រះ។



៣. បន្ទាប់មកមនុស្សប្រព្រឹត្តអំពើបាប ហើយត្រូវ

បានបំបែកចេញពីព្រះ។ យើងទាំងអស់គ្នាបានប្រព្រឹត្តបាប

ហើយត្រូវបានបំបែកចេញពីព្រះ។ ហេតុនេះហើយ

បានជាយើងមិនមានសេចក្ដីសុខសាន្ត។



៤. យើងព្យាយាមស្ដារទំនាក់ទំនងរបស់យើងជាមួយ

ទ្រង់វិញដោយការថ្វាយដង្វាយផ្សេងៗ។ យើងថ្វាយអ្វីៗ

ផ្សេងៗដូចជាខំប្រព្រឹត្តល្អ ប្រឹងប្រឹងរកធម៌អារ និងការ

បម្រើផ្សេងៗ។ ដង្វាយរបស់មនុស្សមិនអាចផ្សះផ្សារ

ទំនាក់ទំនងជាមួយព្រះបាននោះទេ។ យើងនៅតែបែកចេញពីព្រះដដែល។



៥. ព្រះជាម្ចាស់ស្រលាញ់យើង ហើយបានរៀបចំផ្លូវ

សម្រាប់យើងឲ្យយើងទទួលការសង្គ្រោះ។ ទ្រង់ប្រទាន

ព្រះបុត្រាតែមួយរបស់ទ្រងមកយើង។



៦. ព្រះយេស៊ូបានទទួលយកការកាត់សម្រាប់អំពើបាប

របស់យើង។ ទ្រង់ត្រូវបានគេធ្វើគត់នៅលើឈើឆ្កាង។



៧. ទ្រង់ត្រូវបានបញ្ចុះក្នុងផ្នូរ



៨. បីថ្ងៃក្រោយមកទ្រង់មានព្រះជន្មរស់ឡើងវិញ



៩. បើសិនជាយើងជឿ ប្រែចិត្ត ហើយ ដើរតាម

ព្រះយេស៊ូនោះទ្រង់លាងសំអាតអំពើបាបរបស់

យើងឲ្យបានជ្រះស្អាតជារៀងរហូត។



១០. តាមរយៈព្រះយេស៊ូអំពើបាបរបស់យើងត្រូវបាន

អត់ទោសហើយទំនាក់ទំនងរបស់យើងជាមួយព្រះត្រូវ

ស្ដារឲ្យដូចកាលពីដើមដំបូងបង្អស់ឡើងវិញ។



១១. តើលោកអ្នកព្រមជឿ ហើយចាប់ផ្តើមដើរ

ជាមួយព្រះយេស៊ូដែរ ឬទេ? តើលោកអ្នកចង់ឲ្យ

អំពើបាបរបស់លោកអ្នកត្រូវបានអត់ទោសដែរឬទេ?



រ៉ូម១០៖៩ "១ប្រសិនបើមាត់អ្នកប្រកាសថា ព្រះយេស៊ូពិតជាព្រះអម្ចាស់ ហើយបើចិត្តអ្នកជឿថា ព្រះជាម្ចាស់ពិតជាបានប្រោសព្រះយេស៊ូឲ្យមានព្រះជន្មរស់ឡើងវិញមែន នោះអ្នកនឹងទទួលការសង្គ្រោះជាមិនខាន"។

## ការបង្កើតសិស្ស (វាលទី៣)

---

## ការសិក្សា កិច្ចការ ជំពូក២

### សូមអាន កិច្ចការ ២៖៣៧-៤៧

តើអ្នកជឿថ្មីបានធ្វើអ្វីខ្លះ?

ប្រែចិត្ត ហើយជឿ (ខ៣៨)

ទទួលពិធីជ្រមុជទឹក (ខ៣៨, ៤១)

ស្តាប់សេចក្តីបង្រៀន (ខ៤២)

ប្រកបគ្នា (ខ៤២)

ធ្វើពិធីលាងព្រះអម្ចាស់ (ខ៤២, ៤៦)

ទីសម្គាល់ និង ការអស្ចារ្យ, ព្រះវិញ្ញាណបរិសុទ្ធ (ខ៤៣)

ពួកសាវ័ក និង អ្នកដឹកនាំ (ខ៤២,៤៣)

អោយ (ខ៤៤,៤៥)

សេចក្តីស្រលាញ់ (ខ៤៤,៤៥)

ថ្វាយបង្គំ (ខ៤៧)

ដំណឹងល្អ/ពហុគុណ (ខ៤៧)

ចេញពីអត្ថបទគម្ពីរនៅក្នុងកិច្ចការជំពូក២ យើងបានរកឃើញមេរៀនសំខាន់ៗចំនួន៧ដើម្បីបង្រៀនដល់អ្នកជឿថ្មីក្នុងកំឡុងពេលនៃការបង្កើតសិស្សក្នុងរយៈពេលខ្លី។ សម្រាប់មេរៀននិមួយៗមានសាច់រឿង និងបទបញ្ហាដើម្បីសិក្សាដោយប្រើ "ដំណើរការនៃជំហានទាំង៨" និង សំនួរផ្សេងៗ។

វាលទាំង៤ និង ការសិក្សាបន្ថែម

| រាជបញ្ញា៧យ៉ាងរបស់ព្រះគ្រិស្ត | |
|---|---|
| ១. ប្រែចិត្ត ហើយជឿ | សាច់រឿង៖ លូកា១៩៖១-១០<br>រាជបញ្ញា៖ ម៉ាកុស ១៖១៤-១៥ |
| ២. ពិធីជ្រមុជទឹក | សាច់រឿង៖ កិច្ចការ៨៖២៦-៣៩<br>រាជបញ្ញា៖ ម៉ាថាយ២៨៖ ១៩-២០ |
| ៣. ចេញទៅ ហើយផ្សាយដំណឹងល្អ | សាច់រឿង៖ យ៉ូហាន ៤៖១-៤២<br>រាជបញ្ញា៖ ម៉ាកុស១៦៖១៥ |
| ៤. អធិស្ឋាន | សាច់រឿង៖ ម៉ាថាយ ៦៖៥-១៥<br>រាជបញ្ញា៖ ម៉ាថាយ៦៖៩ |
| ៥. សេចក្តីស្រលាញ់ | សាច់រឿង៖ លូកា ១០៖២៥-៣៧<br>រាជបញ្ញា៖ ម៉ាថាយ២២៖៣៧-៣៩ |
| ៦. អោយ | សាច់រឿង៖ ម៉ាកុស ១២៖៤១-៤៤<br>រាជបញ្ញា៖ ម៉ាថាយ ៦៖១-៤ |
| ៧. ពិធីលាងព្រះអម្ចាស់ | សាច់រឿង៖ លូកា ២២៖៧-២០<br>រាជបញ្ញា៖ ម៉ាថាយ ២៦៖២៦-២៩ |

## ដំណើរការនៃជំហានទាំង៨

ខាងក្រោមនេះជាដំណើរការដែលត្រូវបានប្រើជាមួយនឹងអ្នកជឿថ្មីសម្រាប់មេរៀននៃការបង្កើតសិស្ស។ ដំណើរការនេះក៏ត្រូវបានប្រើនៅពេលដែលក្រុមជំនុំត្រូវបានចាប់ផ្តើមជួបជុំគ្នាផងដែរ។

**១. អធិស្ឋាន**

**២. ថ្វាយបង្គំ**

**៣. រំលឹកឡើងវិញ**

ក. តើអ្នកបានរៀនអ្វីខ្លះពេលយើងបានជួបគ្នាកាលពីលើកមុន?

**៤. ការមានគណនេយ្យភាព**

ក. តើអ្នកណាខ្លះដែលអ្នកបានចែកចាយដំណឹងល្អជាមួយ ចាប់តាំងពីយើងបានជួបគ្នាលើកចុងក្រោយ?

ខ. ហើយតើអ្នកបានប្រណិបត្តតាមអ្វីដែលអ្នកបានរៀនតាំងពីពេលដែលយើងបានជួបលើកចុងក្រោយដោយរបៀបណា?

## ៥. សេចក្តីបង្រៀនថ្មី

ក. តើរឿងនេះបង្រៀនយើងអ្វីខ្លះអំពីព្រះជាម្ចាស់?

ខ. តើរឿងនេះបង្រៀនយើងអ្វីខ្លះអំពីមនុស្ស?

គ. តើមានអ្វីខ្លះនៅក្នុងរឿងនេះដែលយើងមិនគួរធ្វើតាម(ជាអំពើបាប)?

ឃ. តើមានអ្វីខ្លះនៅក្នុងរឿងនេះដែលយើងគួរធ្វើតាម?

ង.តើមានបទបញ្ញាអ្វីខ្លះនៅក្នុងរឿងនេះដែលយើងត្រូវប្រណិបត្តតាម?

## ៦. ការអនុវត្តន៏សាកល្បង

## ៧. ផែនការណ៏

## ៨. អធិស្ឋាន

## ការបង្កើតសិស្សរយះពេលវែង

បន្ទាប់ពីបញ្ចប់បទបញ្ញាទាំង៧ អ្នកអាចប្រើសៀវភៅម៉ាកុស ឬក៏សាច់រឿងពីការបង្កើតរហូតដល់ព្រះយេស៊ូសម្រាប់ការបង្កើតសិស្សរយះពេលវែង។ នៅក្នុងដំណើរការទាំង៨ជំហាន រឿងទាំងនេះអាចត្រូវបានប្រើសម្រាប់ជំហានចំនួន ៥ (សេចក្តីបង្រៀនថ្មី) ជាមួយសំនួរដូចគ្នា (តើអ្នករៀនអ្វីខ្លះអំពីព្រះជាម្ចាស់ ។ល។)។ មេរៀននៃការបង្កើតសិស្សរយះពេលវែង ជួយអ្នកជឿថ្មីឲ្យចម្រើនឡើងក្នុងការយល់ដឹងរបស់ពួកគេអំពីសាច់រឿងនៅក្នុងព្រះគម្ពីរពីលោកុប្បត្តិ ដល់វិវរណៈ។

## ការបង្កើតពិភពលោក

១. ការបង្កើតពិភពលោក លោកុប្បត្តិ១៖១-២៖៣

២. ការបង្កើតមនុស្ស លោកកុប្បត្តិ២៖៤-២៥

## សាច់រឿងអំពីអំពើបាប - ការមិនស្តាប់បង្គាប់របស់មនុស្ស

៣. អំពើបាបដំបូង និង ការកាត់ទោស លោកកុប្បត្តិ ៣៖១-២៤

៤. អំពើបាបបានឆ្លងដល់កូនចៅរបស់លោកអដាំ និង នាងអេវ៉ា លោកុប្បត្តិ៤៖១-១៦

៥. អំពីបាបឆ្លងដល់ពិភពលោកទាំងមូល - ទឹកជំនន់ធំ លោកុប្បត្តិ ៦៖១១-២២. ៧៖១១-២៣, ៨៖១៤-២២

## សាច់រឿងអំពីការប្រោសលោះ - ការបង់ថ្លៃនៃបាប និង ការសន្យានៃការលើកលែងទោស

៦. ព្រះបន្ទូលសន្យាចំពោះលោកអប្រាហាំ លោកុប្បត្តិ ១២៖ ១-៩, ១៥៖១-៦

៧. ព្រះផ្គត់ផ្គង់យញ្ញបូជាជំនួសលោកអ៊ីសាក់ លោកុប្បត្តិ ២២៖១-១៩

៨. ពូជពង្សលោកអប្រាហាំជាប់ជាទាសករ ហើយព្រះជ្រើសរើសលោកម៉ូសេឲ្យក្លាយជាអ្នករំដោះ។ និក្ខមនំ ១៖១-១៤, ៣៖១-១៤

៩. បុណ្យរម្លង - ឈាម និង កូនចៀម និក្ខមនំ១២៖១-២៨

១០. ព្រះជាម្ចាស់ប្រទានក្រឹត្តវិន័យ១០ប្រការ និងយញ្ញបូជាសម្រាប់ការល្មើសនឹងក្រឹត្តវិន័យ និក្ខមនំ ២០៖១-២១, លេវីវិន័យ ៤៖១-៤

១១. ប្រជារាស្ត្ររបស់ព្រះបន្តប្រព្រឹត្តអំពើបាប ចៅហ្វាយ២៖១០-២៣

១២. ព្រះជាម្ចាស់នឹងបញ្ជូនអ្នកដែលប្រោសលោះមួយរូប អេសាយ ៩១-៧ និង ៥៣

## ព្រះយេស៊ូយាងមកដើម្បីបំពេញព្រះបន្ទូលសន្យាអំពីការសង្គ្រោះ

១៣. កំណើតព្រះយេស៊ូដោយយោងទៅតាមពាក្យទំនាយ ម៉ាថាយ១៖១-២៥

១៤. ពិធីជ្រមុជទឹករបស់ព្រះយេស៊ូ - មើលហ្ន៎! កូនចៀមនៃព្រះ! សក្ខីភាពអំពីលោកយ៉ូហាន និង ព្រះវិញ្ញាណ។ ម៉ាថាយ៣, យ៉ូហាន១៖២៩-៣៤

**វាលទាំង៤ និង ការសិក្សាបន្ថែម**

១៥. ការល្បួងព្រះយេស៊ូ ម៉ាថាយ៤៖១-១១

១៦. ព្រះយេស៊ូមានសិទ្ធិអំណាចដើម្បីអត់ទោសបាប - បុរសពិការ និង សម្លាញ់៤នាក់

លូកា៥៖១៧-២៦

១៧. ព្រះយេស៊ូមានព្រះចេស្ដាលើធម្មជាតិ - ធ្វើឲ្យសមុទ្រស្ងប់ ម៉ាកុស៤៖៣៥-៤១

១៨. ព្រះយេស៊ូមានសិទ្ធអំណាចលើវិញ្ញាណផ្សេងៗ - បុរសវិញ្ញាណអាក្រក់ចូលនៅតំបន់គេរ៉ាស៊ីន។ ម៉ាកុស ៥៖ ១-២០

១៩. ព្រះយេស៊ូមានព្រះចេស្ដាលើសេចក្ដីស្លាប់ - ព្រះយេស៊ូប្រោសឡាសាឲ្យរស់ពីសេចក្ដីស្លាប់ យ៉ូហាន១១៖១-៤៥

២០. ព្រះយេស៊ូជាព្រះសង្គ្រោះដែលនាំមកនូវជីវិតអស់កល្ប យ៉ូហាន៤៖១-២៦, ៣៩-៤២

**ព្រះបន្ទូលសន្យាត្រូវបានបំពេញ**

២១. អាហារពេលល្ងាចចុងក្រោយ - "នេះជារូបកាយរបស់ខ្ញុំ ហើយនិងលោហិតដែលនឹងបង្ហូសម្រាប់អ្នករាល់គ្នា"។ ម៉ាថាយ២៦៖១៨- ៣០

២២. ព្រះយេស៊ូត្រូវបានគេក្បត់ ចាប់ខ្លួន រងការចោទប្រកាន់ដែលខុស ស៊ូទ្រាំ និង កាត់ទោសប្រហារជីវិត។ យ៉ូហាន ១៨៖ ១ - ១៩៖១៦

២៣. ការឆ្កាង កាសម្រេចចុងក្រោយ និងការទាស់ប្រឆាំងព្រះយេស៊ូ។ "ការបានស្រេចហើយ" យ៉ូហាន១៩៖១៦- ៤២

២៤. ការរស់ឡើងវិញ ការលេចឲ្យពួកសិស្ស និង អ្នកដើរតាមទ្រង់ឃើញ។

លូកា២៤៖១-៣៥

២៥. ព្រះយេស៊ូត្រឡប់ទៅឯព្រះបិតាវិញ ការយាងឡើងទៅស្ថានសួគ៌។ លូកា២៤៖៣៦-៥៣

២៦. ការឆ្លើយតបរបស់យើង - កំណើតថ្មី យ៉ូហាន៣៖១-២១

២៧. ព្រះយេស៊ូនឹងយាងត្រឡប់មកវិញ ១ថែស្សាឡូនិក ៤៖១៣-១៨

## ក្រុមជំនុំ (វាលទី៤)

## ការសិក្សាពីក្រុមជំនុំដែលសមញ្ញ

សូមអានខគម្ពីរផ្សេងៗ ហើយឆ្លើយសំនួទាំងនេះ

១. តើក្រុមជំនុំជានណា?

កិច្ចការ ២៖៣៧-៤១

អ្នកជឿដែលបានទទួលពិធីជ្រមុជទឹក

២. តើក្រុមជំនុំជួបជុំគ្នានៅទីណា?

កិច្ចការ២៖៤៦, រ៉ូម ១៦៖៣-៥

ក្រុមជំនុំអាចជួបគ្នានៅក្នុងផ្ទះ ក្នុងអគារក្រុមជំនុំ នៅក្រោមដើមឈើ។ល។

៣. តើក្រុមជំនុំជួបប្រជុំគ្នានៅពេលណា?

ហេប្រឺ១០៖២៤-២៥

ពេលណាមិនសំខាន់នោះទេ ឲ្យតែពួកជំនុំព្រមព្រៀងគ្នាជួបជុំគ្នាញឹកញាប់ និងទៀតទាត់។

៤. តើហេតុអ្វីបានជាក្រុមជំនុំជួបជុំគ្នា?

១កូរិនថូស១០៖៣១

ដើម្បីថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់

៥. តើក្រុមជំនុំធ្វើអ្វីខ្លះ?

កិច្ចការ២៖៣៧-៤៧ (ដូចជាការសិក្សានៅកិច្ចការជំពូក២ នៅមេរៀនក្នុងវាលទី៣ដែរ)

**វាលទាំង៤ និង ការសិក្សាបន្ថែម**

ប្រែចិត្ត ហើយជឿ ទទួលពិធីជ្រមុជទឹក ស្ដាប់សេចក្ដីបង្រៀន ប្រកបគ្នា ធ្វើពិធីលាងព្រះអម្ចាស់ ទីសម្គាល់ និង ការអស្ចារ្យ, ព្រះវិញ្ញាណបរិសុទ្ធ ពួកសាវ័ក និង អ្នកដឹកនាំ អោយ សេចក្ដីស្រលាញ់ ថ្វាយបង្គំ ដំណឹងល្អ/ពហុគុណ។



## ការបង្កើតគោលដៅ

ចូរប្រើតារាងវាល៤នេះដើម្បីបង្កើតគោលដៅសម្រាប់វាលនីមួយៗដែលអ្នកបានទទួលការបណ្តុះបណ្តាលរួចហើយ។ សូមបង្កើតគោលដៅតែវាលនិងឧបករណ៏ណាដែលអ្នកបានរៀនរួចហើយតែប៉ុណ្ណោះ។ សូមឲ្យគ្រប់គ្នាគូសតារាងវាលទាំង៤ ហើយសរសេរគោលដៅនៅក្នុងវាលនីមួយៗ។ ខាងក្រោមនេះជាគំរូគោលដៅដែលអាចធ្វើទៅបានសម្រាប់វាលនីមួយៗ។

| | |
|---|---|
| **ការចូលទៅកាន់**<br>• តើអ្នកនឹងចែកចាយដំណឹងល្អទៅកាន់អ្នកណាខ្លះពីបញ្ជីអយកុសរបស់អ្នក?<br>• ចូរសុំព្រះជាម្ចាស់ពីកន្លែង និងមនុស្សដែលអ្នកនឹងចេញទៅរក | **ដំណឹងល្អ**<br>• តើអ្នកនឹងចែកចាយដំណឹងល្អប៉ុន្មានដងនៅខែនេះ?<br>• តើអ្នកនឹងបង្ហាត់អ្នកណាឲ្យផ្សាយដំណឹងល្អដោយប្រើឧបករណ៏សាមញ្ញនៅខែនេះ? |
| **ក្រុមជំនុំ**<br>• តើមានក្រុមជំនុំដែលអ្នកនឹងចាប់ផ្តើមប្រើដំណើរការនៃជំហានទាំង៨ដើម្បីជួបជុំគ្នាដែរឬទេ? | **ការបង្កើតសិស្ស**<br>• តើមានអ្នកជឿថ្មីដែលអ្នកនឹងចាប់ផ្តើមជាមួយបទញ្ញាទាំង៧ដែរឬទេនៅខែនេះ? |

**ការអភិវឌ្ឍន៏អ្នកដឹកនាំ**
តើអ្នកមានគម្រោងការណ៏អ្វីដើម្បីជួប "ធីម៉ូថេ" របស់អ្នកនៅខែនេះ?

## ការសិក្សាបន្ថែម និង ប្រអប់ឧបករណ៍

## យុទ្ធសាស្ត្រផ្លែចលឿន

បន្ទាប់ពីការផ្តល់ជូនដោយការអធិស្ឋាន ឬ ចែកចាយទីបន្ទាល់ និង ដំណឹងល្អ អ្នកអាចចែកចាយរឿងទាំងនេះជាមួយអ្នកមិនជឿ ហើយមិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការជឿនៅឡើយប៉ុន្តែចង់ឮថែមទៀតពីព្រះយេស៊ូ។

### សាច់រឿងនៃព្រះចេស្តារ

១. ព្រះយេស៊ូមានព្រះចេស្តារលើធម្មជាតិ - ម៉ាកុស៤៖៣៥-៤១

២. ព្រះយេស៊ូមានព្រះចេស្តារលើវិញ្ញាណអាក្រក់ - ម៉ាកុស៥៖១-២០

៣. ព្រះយេស៊ូមានព្រះចេស្តារលើជំងឺផ្សេងៗ - ម៉ាកុស ៥៖២៥-៣៤

**វាលទាំង៤ និង ការសិក្សាបន្ថែម**

## ការសិក្សាពីពិធីជ្រមុជទឹក

សូមអានអត្ថបទគម្ពីរទាំងនេះហើយបំពេញក្នុងតារាងខាងក្រោមៈ

| | **តើអ្នកទទួលពិធីជ្រមុជទឹក** | **តើអ្នកណាអ្នកធ្វើពិធីជ្រមុជទឹកឲ្យ?** | **នៅពេលណា?** |
|---|---|---|---|
| យ៉ូហាន ៤៖១-២ | អ្នកជឿ | សិស្សរបស់ព្រះយេស៊ូ | ? |
| កិច្ចការ ២៖៣៦-៤១ | អ្នកជឿ ៣០០០ នាក់ | ? | នៅថ្ងៃនោះ |
| កិច្ចការ ៨៖៣៦-៣៨ | លោកអាមាថ | លោកភីលីព | ភ្លាមៗ |
| កិច្ចការ៩៖៣-១៨ | លោកសូល | អាណាណាស | ៣ថ្ងៃបន្ទាប់ពីងងឹតភ្នែក និងតមអាហារ |
| កិច្ចការ១០៖២៤, ៤៤-៤៨ | កូណេលាស និង គ្រួសាររបស់គាត់ | ? | បន្ទាប់ពីឮព្រះបន្ទូល ហើយទទួលព្រះវិញ្ញាណបរិសុទ្ធ |
| កិច្ចការ ១៦៖ ១៣-១៥ | នាងលីឌា និង គ្រួសារ | ? | ភ្លាមៗ |
| កិច្ចការ១៦៖៣១-៣៤ | ឆ្មាំគុកនៅក្រុងភីលីព និងគ្រួសារ | ? | ភ្លាមៗ |
| កិច្ច១៨៖៨<br>(១កូរិន១៖១៤) | លោកគ្រីសប៉ុស គ្រួសារ និងអ្នកក្រុងកូរិនថូសជាច្រើន | លោកប៉ូល និង សិស្សរបស់លោក | បន្ទាប់ពីជឿ |
| កិច្ចការ១៩៖១-៧ | សិស្សលោកយ៉ូហាន | ? | បន្ទាប់ពីឮអំពីព្រះវិញ្ញាណបរិសុទ្ធ និង ពិធីជ្រមុជទឹករបស់ព្រះយេស៊ូ |
| **ការសន្និដ្ឋាន** | **អស់អ្នកដែលបានជឿ** | **សិស្ស** | **ភ្លាមៗបន្ទាប់ពីបានជឿ** |